# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១៤៦៦ អយក.ប្រក

## ប្រកាស
## ស្តីពី
## ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញាឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បកចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៤ ស្តីពីការប្រែក្លាយមហា វិទ្យាល័យគរុកោសល្យទៅជាវិទ្យាស្ថានជាតិអប់រំ
- បានឃើញប្រកាសលេខ១៧៨ អយក.ប្រក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកំណត់តួនាទីបេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ របស់វិទ្យាស្ថានជាតិអប់រំ
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់អំពី ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពីៈ

- លក្ខខណ្ឌនៃការបណ្តុះបណ្តាលនិងលក្ខខណ្ឌនៃការជ្រើសរើសនិស្សិតឱ្យចូលរៀន
- លក្ខខណ្ឌនៃការបញ្ចប់ការសិក្សានិងការទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំ។

## ជំពូកទី២

## លក្ខខណ្ឌនៃការបណ្តុះបណ្តាល និងការជ្រើសរើសនិស្សិត

**ប្រការ៤.-**

អនុញ្ញាតឱ្យវិទ្យាស្ថានជាតិអប់រំ បើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ក្នុងរយៈពេល១ឆ្នាំ បន្ថែមលើការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់បរិញ្ញាបត្របូកមួយដែលមានស្រាប់រួចមកហើយ។

**ប្រការ៥.-**

កម្មវិធីសិក្សានេះមានចំនួនក្រេឌីតសរុប ចំនួន៤៥ ក្រេឌីត។

**ប្រការ៦.-**

វិទ្យាស្ថានជាតិអប់រំមានភារកិច្ចដូចខាងក្រោមៈ

- រៀបចំលក្ខខណ្ឌលម្អិតសម្រាប់ជ្រើសរើសនិស្សិតឱ្យចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន
- សហការជាមួយអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាល ឱ្យស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ ការអភិវឌ្ឍរបស់ប្រទេសនិងពិភពលោក ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់គ្រងការសិក្សា ការបង្រៀន ការប្រឡង ការវាយតម្លៃនិក្ខេបបទ និងការប្រគល់សញ្ញាបត្រ
- រៀបចំបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាស្ថាពរ ដើម្បីសុំការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា និងការបណ្តុះបណ្តាលប្រចាំឆមាស ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី ៣

## លក្ខខណ្ឌនៃការបញ្ចប់ការសិក្សា និងការទទួលសញ្ញាបត្រ

**ប្រការ៧.-**

និស្សិតដែលបានបំពេញគ្រប់លក្ខខណ្ឌនៃការបណ្តុះបណ្តាល និងទទួលបានជោគជ័យក្នុងការការពារនិក្ខេបបទបញ្ចប់ត្រូវទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ពីវិទ្យាស្ថានជាតិអប់រំ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

ដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានរៀនចប់កម្មវិធីសិក្សា និងគ្រប់ក្រេឌីត
- បានប្រឡងបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជា
- បានសរសេរនិងការពារនិក្ខេបបទស្រាវជ្រាវចប់ដោយជោគជ័យដែលទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៨.-**

និស្សិតដែលទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ត្រូវទៅបំពេញភារកិច្ចនៅសាលារៀនជំនាន់ថ្មី ឬកន្លែងថ្មីដទៃទៀត តាមការចាត់តាំងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ៩.-**

ប្រកាសលេខ៨៨៣ អយក.ប្រក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ ស្តីពីការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិទ្យាសាស្ត្របង្រៀន នៅវិទ្យាស្ថានជាតិអប់រំ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយិកានៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៩

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក
- ដូចប្រការ១០

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ នា.នីតិកម្ម